# សេចក្តីថ្លែងការរួម

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣

## សូមអំពាវនាវឲ្យបញ្ចប់នូវការគំរាមកំហែង និង សូមចាប់ផ្តើមឲ្យមានការស៊ើបអង្កេត

យើងខ្ញុំជាសហព័ន្ធសហជីព និងអង្គការគាំទ្រវិស័យការងារនានាដែលមានឈ្មោះដែលមានឈ្មោះដូចខាងក្រោម សូមសម្តែងនូវការខកចិត្ត យ៉ាងក្រៃលែងបំផុតចំពោះ នូវកង្វះខាតឆន្ទៈរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការអនុញ្ញាត ឲ្យមានការស៊ើបអង្កេតឯ ករាជ្យមួយទៅនឹងភាពមិនប្រក្រតីនានានៃការបោះឆ្នោតជាសកល។

យើងខ្ញុំសូមជម្រាបជូនភាគីពាក់ព័ន្ធទាំងអស់ រួមមាននិយោជក អ្នកបញ្ជា ទិញអន្តរជាតិ និងអង្គការស្ថាប័នទាំងអស់ឲ្យបានជ្រាបថា បច្ចុប្បន្ននេះ តាមការប៉ាន់ប្រមានអវត្តមានរបស់កម្មករនិយោជិតនៅ កន្លែងការងារត្រូវបានគេមើលឃើញដោយមិនមានមន្ទិលថា មានការកើនឡើងប្រហែលជា២០% ដែលនេះជាលទ្ធផលនៃការបង្ករឲ្យមានការភ័យខ្លាច និងជាល្បែងបង្ហាញពីអំណាចរបស់គណៈបក្សនយោបាយ។

យើងខ្ញុំសូមថ្កោលទោស ចំពោះវត្តមានរបស់កងកម្លាំងប្រដាប់អាវុធនៅក្នុ ងទីក្រុងភ្នំពេញ ហើយសូមបញ្ជា ក់ថា វាមិនមានភាពចាំបាច់ទាល់តែសោះ និងក៏មិនមានការស្វាគមន៍ជាដាច់ខាតនូវវត្តមានកងកម្លាំងប្រដាប់អាវុធនៅក្នុ ងរាជធានីនៃប្រទេសមួយ ព្រមទាំងកាយវិកាដែលគួរឲ្យអស់សំណើចមានដូចជាការទទួលយកនូវគ្រឿងសព្វាវុធពីប្រទេសចិន កាលពីថ្ងៃអង្គារទី៣០ ខែកក្កដាខែមុននេះ។ ជាងនេះទៀត សេចក្តីថ្លែងការណ៍របស់ក្រសួងសង្គមកិច្ចដែលអំពាវនាវ ឲ្យមានភាពស្ងប់ស្ងាត់ ប៉ុន្តែនៅក្នុងប្រយោគនោះបានបង្កប់នូវសារគំរាមកំហែងឲ្យមានសង្គ្រាមស៊ីវិលទៅវិញទេ។

ខណៈនេះ ការបន្តនូវសង្វាក់ផលិតកម្មនៃទំនិញ និងសេវាកម្មនៅកម្ពុជា នឹងចុះថយ។

តាងនាមឲ្យសមាជិកសហព័ន្ធសហជីព យើងសូមអំពាវនាវដល់កងកម្លាំងប្រដាប់អាវុធទាំងអស់មេត្តា ត្រឡប់ទៅមូលដ្ឋានដើមរបស់ខ្លួន រៀងៗខ្លួនវិញ និងបញ្ចប់ជាបន្ទាន់នូវរាល់ទម្រង់នៃការគំរាមកំហែងទាំងអស់។

យើងសូមទាមទារឲ្យមានការស៊ើបអង្កេតដ៏ឯ ករាជ្យ និងមានតម្លាភាពមួយ ទៅលើភាពមិនប្រក្រតី ទាំងឡាយនៃការបោះឆ្នោតនេះ ដែលធាជឿទុកចិត្តបានដល់សមាជិករបស់យើង ដើម្បី ធានាឲ្យមានស្ថិរភាពនៅក្នុងប្រទេសជាតិ និងទំនាក់ទំនងការងាររបស់ខ្លួនផងនោះ។

យើងសូមអំពាវនាវឲ្យមានសាមគ្គីភាពពីដៃគូ សហជីពអន្តរជាតិនានា និងអង្គការគាំទ្រវិស័យការងារទាំងឡាយ ក្នុងការធានាឲ្យមានការស៊ើបអង្កេត ដែលឆ្លុះបញ្ចាំងឲ្យឃើញអំពីសិទ្ធិ និងជីវភាពរស់នៅរបស់យើងត្រូវបានគោរព។

ស្ថាប័នគាំទ្រ៖

1- សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា **(FTUWKC)**, លោក ជា មុន្នី ០១២៩៤១ ៣០៨

2- សម្ព័ន្ធសហជីពជាតិ (NTUC) លោក ហ្វា សាលី ០១៧៣៥៧៣៦៧

3- សមាគមមន្ត្រីរាជការឯករាជកម្ពុជា (CICA) លោក កៅ ពឿន ០១២ ៩៥៨ ៩៧៨

4- សហភាពសហជីពកម្ពុជា(CCU) លោកស្រី យ៉ង់ សោភ័ណ្ឌ ០១២៨៨០០៣៩

5- សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា (BWTUC) លោក វ៉ាន ថុល ០១២ ៧៣៦ ២៧០

6- មណ្ឌលព័ត៌មានកម្មករ (WIC) កញ្ញា សុខ ថាវេត ០៨១៦៣៩៧៧៧

7- មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) លោក យ៉េង វីរៈ ០៦៦៧៧៧០០០

8- សមាគមប្រជាធិបតេយ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA), លោក វន ពៅ 012 534 796

9- ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា(CWC) លោក រ៉ុង ឈុន ០១២ ៩៣០ ៧០៦

10-សម្ព័ន្ធសហជីពចំណីអាហារនិងសេវាកម្មកម្ពុជា(CFSWF), លោក ស មូរ៉ា 016525781

11-បណ្តាញយុវជនកម្ពុជា(CYN), លោក ទឹម ម៉ាឡៃ 017990689)

12-សម្ព័ន្ធសហគមន៍កសិករកម្ពុជា(CCFC), លោក ថេង សាវឿន 078 225 088

13-សហភាពការងារកម្ពុជា (CLC) លោក អ៊ាធន់ ០១២ ៩៩៨ ៩០៦

14-**បណ្តាញកម្មករធ្វើការតាមផ្ទះកម្ពុជា**(CDWN) កញ្ញា វន សម្ផស្ស 0973534550

15-សមាគមអ្នកប្រជាធិប្បតេយ្យ (AOD) លោកស្រី ហួន ផាន់ណារី ០១២ ៣៣៥ ៨២០